

# វិធីដាំគ្រលែន

**១. ការរៀបចំរណ្តៅ:**

- ត្រូវជីករណ្តៅ ៦តឹកបួនជ្រុង និង ជំរៅ ៦តឹក




- រោយកំបោរសប្រមាណ២ស្លាបព្រាបាយ ក្នុងរណ្តៅ។
- ត្រូវដាក់ផេះ ឬ អង្កាម កំប្លោក ចំបើង ពុក អាចម៍មាន់ឬអាចម៍ជ្រូក ឬអាចម៍ គោមួយស្រទាប់កំរាស់ ១តឹក រួចដាក់ដីពី លើ១តឹក ធ្វើយ៉ាងនេះ រហូតទាល់តែពេញរណ្តៅ។




- ត្រូវទុករណ្តៅរៀបចំហើយក្នុងរយៈពេល ២ ទៅ ៣អាទិត្យ។
- ចំងាយពីរណ្តៅមួយទៅរណ្តៅមួយមាន ប្រវែង ៨ ម៉ែត្រ។

**២. ការដាំ:**

- កូនគ្រលែនត្រូវរក្សាផ្សាំទុក ១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹក២ថ្ងៃមុនដាំដើម្បីកុំអោយបែកដី និងឫស។
- មុនដាំត្រូវជញ្ជូនកូនគ្រលែនដាក់ក្បែររណ្តៅទាំងអស់។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- កប់កូនគ្រលែនក្នុងរណ្តៅដោយធ្វើយ៉ាងណាអោយដីកន្ទោងកូនគ្រលែនស្មើមាត់រណ្តៅ រួចយកមែកឈើ ដោតក្បែររណ្តៅចងទប់ ជាមួយកូនគ្រលែន។



- លប់ដីបន្តិចម្តងៗដោយសង្កត់ថ្នមៗ ហាមសង្កត់លើដីកន្ទោងកូនគ្រលែនដែលបណ្តាលអោយដាច់ឫស។

**៣. ការថែទាំ និងដាក់ជី:**

- ខែវស្សាត្រូវពូនគល់ការពារទឹកជាំនៅគល់បណ្តាលអោយរលួយឫស។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉ន ដោយប្រើជីអាចម៍មាន់ ឬអាចម៍ជ្រូក ឬអាចម៍គោ លាយជាមួយអង្កាមពុក ចំបើង ឬកំប្លោក រលួយកាយកប់ក្នុងដីធ្វើជាកំពែង។
- ប្រសិនបើកូនគ្រលែនមានសត្វល្អិតស៊ីត្រួយ ត្រូវប្រើថ្នាំសំលាប់សត្វល្អិត (ណ៉ាត្ញ)។

